ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែសីហា និងទិសដៅការងារខែកញ្ញា ឆ្នាំ២០១៨

**សេចក្តីផ្តើម:**

*នៅក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម និងមមាញឹកលើគ្រប់ការដ្ឋាន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនបានល្អប្រសើរតាមរយៈលទ្ធផលសំខាន់ៗដូចខាងក្រោម៖*

**I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា:**

**១.មុខងារនីតិកម្ម:**

| *រចនាសម្ព័ន្ធនយោបាយ* | *រចនាសម្ព័ន្ធរដ្ឋបាល* |
|---|---|
| | - *បានសម្អាត តុបតែងសាល ផ្គត់ផ្គង់ និងផ្តល់សេវាកេសជ្ជៈ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំផ្សេងៗ សរុបចំនួន០៣លើក*<br>- *បានថតចម្លងឯកសារចំនួន១,១០៣ច្បាប់ អស់ក្រដាសចំនួន១០,៤២៦សន្លឹក*<br>- *បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន០៣លើក*<br>- *បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៣០នាក់ ស្មើនឹង០២លើក*<br>- *បានធ្វើកំណត់បង្ហាញលើព្រះរាជក្រម ព្រះរាជក្រឹត្យ* |

| | |
|---|---|
| | អនុក្រឹត្យ ប្រកាស ដីកាអម សេចក្តីសម្រេច និង លិខិតផ្សេងៗចំនួន៧៣ច្បាប់<br>- បានសិក្សាស្រាវជ្រាវ និងធ្វើឯកសារជំនួយស្មារតី លើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់<br>- បានស្រាវជ្រាវ បកប្រែ និងសង្ខេបព័ត៌មាន សកាអន្តរជាតិបានចំនួន១៩២ច្បាប់<br>- បានចុះត្រួតពិនិត្យប្រព័ន្ធសំឡេង និងការម៉ាវីដេអូ នៅសាលប្រជុំពេញអង្គ និងសាលប្រជុំគណៈ-កម្មាធិការអចិន្ត្រៃយ៍ចំនួន១០លើក<br>- បានប្រចាំការថតសំឡេង ថតវីដេអូ និងរៀបចំ ប្រព័ន្ធសំឡេងចំនួន០៤លើកៗ |

**២.មុខងារតំណាង**:

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា:<br>+ អញ្ជើញដឹកនាំអង្គប្រជុំស្តីពី ការត្រៀម រៀបចំបុណ្យខួបលើកទី៤០ឆ្នាំ នៃទិវា ជ័យជម្នះ៧មករា<br>+ អញ្ជើញចូលរួមក្នុងពិធីប្រកួតកីឡាវាយ កូនគោលផ្នែកនារី Cambodia Glolf & Country Club ដើម្បីជាការលើកទឹកចិត្ត ចំពោះវិស័យកីឡាវាយកូនគោលផ្នែកនារី នៅខេត្តកំពង់ស្ពឺ<br>+ អញ្ជើញចុះពិនិត្យស្ថានភាពទឹកជំនន់ ស្ទឹងព្រែកស្នោត ដែលកំពុងគំរាមកំហែង កាន់តែខ្លាំងដល់ប្រជាពលរដ្ឋរស់នៅ ភូមិសាស្ត្រ ខណ្ឌដង្កោ រាជធានីភ្នំពេញ<br>+ អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធ និងអញ្ជើញជាអធិបតី | - រៀបចំបែបបទ ផ្តល់សេវា អមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះ មូលដ្ឋាន ចូលរួមក្នុងកិច្ចប្រជុំ និងជាគណៈអធិបតី ក្នុងពិធីផ្លូវការផ្សេងៗសរុបចំនួន២៨១លើក<br>- បានផ្តល់សេវារដ្ឋបាល ពិធីការ និងទំនាក់ទំនង ក្នុងការចុះបេសកកម្មអមដំណើរក្រុមសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះ-សំណាលជាមួយមន្ត្រីរាជការ ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋ ព្រមទាំងបានប្រគេនទៀនវស្សា ទេយ្យទាន ទេយ្យវត្ថុ និងបច្ច័យដល់ព្រះសង្ឃដែល គង់ចាំព្រះវស្សានៅខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម<br>- បានរៀបចំទីកន្លែងសម្រាប់សិក្ខាសាលា វគ្គបណ្តុះ-បណ្តាល និងពិធីផ្សេងៗចំនួន០៤លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកា ព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន |

| | |
|---|---|
| ប្រទានភ្លើងបូជាសព ឯកឧត្តម **ស ថេង** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>+ អញ្ជើញជ្រាវព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាទាំង៧សណ្តានរបស់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភានៅខេត្តកណ្តាល<br>+ អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីសាធារណរដ្ឋបារាំងទៅពិនិត្យនិងព្យាបាលជំងឺជូនប្រជាពលរដ្ឋនៅខេត្តកណ្តាល<br>+ អញ្ជើញចូលរួមវេទិកាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងគណបក្សនយោបាយទាំង២០ ដែលបានចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា<br>- ព្រឹទ្ធសភាបានទទួលពាក្យបណ្តឹងចំនួន ០២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៥ករណី និងទទួលពាក្យបណ្តឹងពីក្រសួង ស្ថាប័ន ដែលចម្ងាយជូនមកព្រឹទ្ធសភាជ្រាបចំនួន១០ករណី<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញទូទាំងប្រទេសចំនួន១៩៦លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុម | ព្រឹទ្ធសភាចំនួន៥១នាក់ ស្មើនឹង១៦ច្បាប់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភាចំនួន០៦រូប ស្មើនឹង០៦ច្បាប់<br>- បានថតចម្ងាងឯកសារបានចំនួន៤០ច្បាប់ អស់ក្រដាសចំនួន២០,០០០សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន៩៨នាក់ ស្មើនឹង៤២លើក<br>- បានទទួលលិខិតចូលចំនួន១,៣៦៦ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣៩០ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន៨៩លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៤៥នាក់ ស្មើនឹង០៣លើក<br>- បានចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០១លើក<br>- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន០៦នាក់<br>- បានរៀបចំអំណោយ៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ និងកុមារកំព្រា<br>- ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានចូលរួមជាសមាជិកគាំទ្របរិច្ចាគថវិកា |

| | |
|---|---|
| ប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្សេងៗ និងពិធីផ្សេងៗសរុបចំនួន៧៧លើក។ | ជូនមូលនិធិគន្ធបុប្ផាកម្ពុជា តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (លើកទី២)<br>- បានផ្តល់អត្ថបទព័ត៌មាន និងរូបថតចំនួន ២៣៣សន្លឹក ជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅចំនួន២៥០នាក់ អនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន៣៨ក្បាល និងសងវិញចំនួន៣៥ក្បាល ព្រមទាំងបានធ្វើកាតសមាជិកបណ្ណាល័យជូនសិស្ស និងនិស្សិតចំនួន១០នាក់<br>- បានទទួលឯកសារ សៀវភៅ ព្រឹត្តិបត្រ ទស្សនាវដ្តីចំនួន៤៨៨ក្បាល កាសែត និងព្រះរាជក្រមចំនួន១៩៧ច្បាប់ ពីអង្គការ ស្ថានទូត ក្រសួងស្ថាប័ន វិទ្យាស្ថានអប់រំ សប្បុរសជន និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានផលិតប័ណ្ណរថយន្តចេញ និងចូលបរិវេណព្រឹទ្ធសភាឆ្នាំ២០១៩ចំនួន៣,០០០ប័ណ្ណ និងកំពុងរៀបចំផលិតសៀវភៅនិនានុលេខន៍ ប្រតិទិន និងប្រតិទិនផែនការខែ ឆ្នាំ២០១៩<br>- បានផលិតប័ណ្ណស្តីពី ព្រឹទ្ធសភានីតិកាលទី៤ ជាបីភាសា<br>- បានរៀបចំទស្សនាវដ្តីប្រចាំខែកក្កដា ឆ្នាំ២០១៨<br>- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភាចំនួន៤៨លើក<br>- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃសរុបចំនួន៤៨លើក<br>- បានធ្វើបច្ចុប្បន្នភាព និងលេខទូរស័ព្ទក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នីតិកាលទី៤ ដើម្បី |

| | |
|---|---|
| | ទុកជាឯកសារជំនួយស្មារតី។ |

**៣.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| - សម្តេចវិបុលសេនាកត្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានទទួលជួបសម្តែងការគួរសម និងជម្រាបលា ជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតឡាវ រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋឥណ្ឌា គណៈប្រតិភូក្រសួងទំនាក់ទំនងអន្តរជាតិនៃគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តចិន<br>- ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា បានជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយប្រធានក្រុមហ៊ុន ZETA Espace Antibes Route De Grasse និងសហការី ដែលមកពីសាធារណរដ្ឋបារាំង ព្រមទាំងអនុប្រធានគណៈកម្មាធិការសភាប្រឹក្សានយោបាយប្រជាជនចិនប្រចាំខេត្តឡៅនីងនៃសាធារណរដ្ឋប្រជាមានិតចិន<br>- សមាជិក សមាជិកាព្រឹទ្ធសភា បានអនុញ្ញាតឱ្យប្រធានលេខាធិការគណៈកម្មការអប់រំសភាសហព័ន្ធវ៉ាល់ឡូនីព្រុចសែល ប្រធានអង្គការសុខភាពពិភពលោក (WHO) នាយកប្រតិបត្តិវិទ្យាស្ថានសន្ធនាមេគង្គ(MDI) ប្រធានទូរទស្សន៍ NHK JAPAN និងលោក Yamamota ចូលជួបសម្តែងការគួសមសវនាការនិងពិភាក្សាការងារ<br>- សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមវេទិកាសភាតំបន់អាស៊ី-ប៉ាស៊ីហ្វិចលើកទី៤ | - បានរៀបចំពិធីបដិសណ្ឋារកិច្ច ដំណើរទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូអន្តរជាតិ ឥស្សរជននយោបាយ អគ្គទូត និងអង្គការអន្តរជាតិនានា<br>- បានរៀបចំទីកន្លែងសម្រាប់ជំនួបសម្តែងការគួរសម និងជម្រាបលាចំនួន០៥លើក<br>- បានបត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំជួបក្ងៀវជាតិ និងអន្តរជាតិ មកបំពេញទស្សនកិច្ចនៅព្រឹទ្ធសភាចំនួន១៥លើក<br>- បានរៀបចំសម្ភាត តុបតែងសាល ផ្គត់ផ្គង់សម្ភារៈអនាម័យ បម្រើសេវាកេសជ្ជៈ និងអាហារសម្រន់ក្នុងកិច្ចប្រជុំចំនួន១២លើក<br>- បានបតចម្លងឯកសារចំនួន១០០ច្បាប់ អស់ក្រដាសចំនួន៧១៤សន្លឹក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញចំនួន២៣នាក់ ស្មើនឹង១៤លើក<br>- បានធ្វើកំណត់បង្ហាញ កំណត់ហេតុ កំណត់ទូតសំណើ និងលិខិតឆ្លើយតបទៅក្រសួង ស្ថាប័នផ្សេងៗ និងបណ្តាអគ្គទូតនានាចំនួន១៤លើក<br>- ធ្វើលិខិតទៅក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីសុំជំនួយស្មារតីចំនួន០៣លើក<br>- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន |

| | |
|---|---|
| ស្តីពី សុខភាពពិភពលោក នៅសាធារណ-រដ្ឋហ្វីលីពីន និងចូលរួមពិធីសំណេះសំណាល និងសួរសុខទុក្ខពាណិជ្ជករជនជាតិខ្មែរចំនួន ១០០នាក់ នៅសហរដ្ឋអាមេរិក។ | ព្រឹទ្ធសភាចំនួន៣៩នាក់ ស្មើនឹង០៦ច្បាប់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងទូទាត់ការចំណាយផ្សេងៗចំនួន១៥លើក<br>- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំផ្សេងៗ ដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១២៥នាក់ ស្មើនឹង១០លើក<br>- ថ្នាក់ដឹកនាំអគ្គលេខាធិការព្រឹទ្ធសភា បានជួបពិភាក្សាការងារជាមួយអគ្គលេខាធិការរដ្ឋសភានៃប្រទេសនូវែលសេឡង់ និងគណៈប្រតិភូអគ្គ-លេខាធិការព្រឹទ្ធសភានៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន<br>- បានរៀបចំបែបបទជូនគណៈប្រតិភូសមាជិកព្រឹទ្ធសភា អញ្ជើញទៅចូលរួមវេទិកា និងសំណេះសំណាល សួរសុខទុក្ខពាណិជ្ជករជនជាតិខ្មែរនៅក្រៅប្រទេសចំនួន០២លើក<br>- បានទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន និងបណ្ណាល័យនានា ដើម្បីសុំ និងទទួលសៀវភៅ ព្រឹត្តិបត្រ និងសម្ភារៈដល់កិច្ចការអន្តរជាតិ ដំណើរទស្សនកិច្ច សិក្ខាសាលា បេសកកម្ម ក្នុង និងក្រៅប្រទេស ស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។ |

**៤.មុខងារអភិវឌ្ឍន៍ស្ថាប័ន :**

| រចនាសម្ព័ន្ធនយោបាយ | រចនាសម្ព័ន្ធរដ្ឋបាល |
|---|---|
| | + បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៨៤ច្បាប់<br>- រៀបចំចងក្រងសម្រង់ស្តិតិ បទបង្ហាញ រចាយ- |

| | |
|---|---|
| | ការណ៍ស្តីពី សកម្មភាពការងារព្រឹទ្ធសភា និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែសីហា ឆ្នាំ២០១៨ ព្រមទាំងបានផ្សព្វផ្សាយទៅតាម អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៧០ច្បាប់។<br>+ ការងារគ្រប់គ្រងបុគ្គលិក:<br>- បានរៀបចំលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការសរុបចំនួន៥៥ច្បាប់<br>- ប្រជុំពិភាក្សាការងារជាមួយគណៈគ្រប់គ្រងសាលាភូមិន្ទរដ្ឋបាល<br>- ប្រជុំពិនិត្យកែសម្រួលរចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់អគ្គនាយកដ្ឋានទាំង៣ និងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានថ្មី<br>- បានធ្វើបែបបទស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសមត្ថកិច្ចនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។<br>+ ការងារបណ្តុះបណ្តាលធនធានមនុស្ស:<br>- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន ០៣វគ្គ មានសិក្ខាកាមសរុបចំនួន៣៩នាក់។<br>+ ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ:<br>- បានប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ប្រជុំរៀបចំគោលការណ៍ហិរញ្ញវត្ថុសម្រាប់នីតិកាលទី៤ ព្រឹទ្ធសភា<br>- ប្រជុំឆ្នាំគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងកម្រិត |

| | |
|---|---|
| | នយោបាយ<br>- បានរៀបចំរបាយការណ៍ចំនួនមន្ត្រីក្របខ័ណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យា របាយការណ៍ប្រាក់បៀវត្សប្រាក់បំណាច់ និងប្រាក់វិភាជន៍ផ្សេងៗ និងរបាយការណ៍ចំណាយថវិកាធៀបអាណត្តិប្រចាំខែ ព្រមទាំងធ្វើតារាងប្រាក់ឧបត្ថម្ភរបស់ថ្នាក់ដឹកនាំមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារផ្សេងៗ និងអាហារសម្រន់សម្រាប់កិច្ចប្រជុំនានាចំនួន ១៨សំណើ បានផ្គត់ផ្គង់សម្ភារៈអនាម័យ សម្ភារៈការិយាល័យ និងកេសជ្ជៈចំនួន ៥៣សំណើ សម្រាប់កិច្ចប្រជុំផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>- បានរៀបចំសម្អាត តុបតែងសាលប្រជុំ ផ្តល់សេវាកេសជ្ជៈ និងអាហារសម្រន់ក្នុងពិធីផ្សេងៗចំនួន ១៥លើក មានអ្នកចូលរួមចំនួន៦១៩នាក់<br>- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន២៥៦លើក<br>- បានថតចម្លងឯកសារចំនួន ៥,៩៣៣ច្បាប់ និងចងក្រងសៀវភៅចំនួន៧៩ក្បាល អស់ក្រដាសចំនួន២៤,០២៩សន្លឹក និងជួសជុលសម្អាតម៉ាស៊ីនថតចម្លង និងម៉ាស៊ីនព្រីនធ័រចំនួន១៨លើក<br>- បានផ្តល់សេវាដឹកជញ្ជូនជូនថ្នាក់ដឹកនាំ សមាជិកសមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងរាជធានីភ្នំពេញចំនួន |

| | |
|---|---|
| | ១២នាក់ ស្មើនឹង០៨លើក។<br>+ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្តរឹង និងទន់ :<br>- ត្រៀមកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានសភាកម្ពុជា(PIC) តាមការប្រែប្រួលថ្មី ដែលយកប៉ូលតំបន់ជាឧត្តមភាព<br>- កសាងអគារថ្មី០១ខ្នង សម្រាប់វិទ្យាស្ថានសភាកម្ពុជា(PIC)<br>- រៀបចំជួសជុលអគារនាយកដ្ឋាន ICT Studio និងបន្ទប់សម្រាប់អ្នកសារព័ត៌មាន<br>- ជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារបណ្តាញទឹក និងផ្គាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងប្រគល់សម្ភារៈជូនគណៈកម្មការទី១០ ព្រមទាំងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សរុបចំនួន៤០៤គ្រឿង<br>- បានរៀបចំកែលម្អបរិស្ថានក្នុងបរិវេណព្រឹទ្ធសភាឱ្យមានសោភ័ណភាពល្អ<br>- បានតាំងពិព័រណ៍រូបភាពចំនួន០៤លើក<br>- សហការជាមួយក្រុមហ៊ុនកំចាត់សត្វកណ្តៀរ និងសហការប្រចាំការម៉ាស៊ីនភ្លើង នៅតាមសាលប្រជុំ ព្រមទាំងបានត្រួតពិនិត្យមើលការប្រើប្រាស់ទឹក ភ្លើង ក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាក សរុបចំនួន៥៣លើក<br>- ចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Connect Wifi និងជួសជុលម៉ាស៊ីនកុំព្យូទ័រ ដាក់កម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធី Unicode និង Set up កម្មវិធីសរុបចំនួន៧២គ្រឿង។ បានUpload សេចក្តីជូនដំណឹង |

| | |
|---|---|
| | ព្រឹត្តិបត្រព័ត៌មានសុខភាព ទស្សនាវដ្តី និងរូបភាពសកម្មភាពការងាររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាសរុបចំនួន២៧ចំណងជើង។<br>+ ការងារផ្សេងៗ :<br>- បានផលិតព័ត៌មានទាន់ហេតុការណ៍ និងផលិតខ្សែវីដេអូ សម្រាប់បង្ហោះលើ Alert News ចំនួន ៤៩ប្រធានបទ<br>- ថត និងផ្សព្វផ្សាយសកម្មភាពថ្នាក់ដឹកនាំក្នុងកម្មវិធីផ្សេងៗចំនួន២២លើក<br>- បានចុះបញ្ជីសៀវភៅ បោះត្រា បិទបិណ្ណខ្ចី និងសងសៀវភៅ អ៊ុតក្របសៀវភៅ បញ្ចូលសៀវភៅ ភាសាអង់គ្លេសក្នុងកម្មវិធី KOHA និងបញ្ជូនសៀវភៅដាក់នៅសាលអាន ព្រមទាំងជួសជុលឯកសារ និងសៀវភៅចាស់ៗ និងរៀបចំទុកដាក់ទស្សនាវដ្តីច្បាប់ ព្រឹត្តិបត្រ និងជំនាញផ្សេងៗ សរុបចំនួន៨០១ក្បាល<br>- បញ្ចូលទិន្នន័យសៀវភៅព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ច្បាប់ កាសែត ទស្សនាវដ្តី ព្រឹត្តិបត្រ រាជកិច្ច និងបញ្ចូលសៀវភៅតាមE-Library តាមបណ្តាញ Facebook សរុបចំនួន៦,៣៦៥ក្បាល។ |

**II.ទិសដៅការងារខែកញ្ញា ឆ្នាំ២០១៨**

-ត្រៀមសហការជាមួយរដ្ឋសភានីតិកាលទី៦ និងរាជរដ្ឋាភិបាលអាណត្តិថ្មី និងការចូលរួមមហាសន្និបាតAIPA នៅសាធារណរដ្ឋសិង្ហបុរី។

**១.មុខងារនីតិកម្ម**:

-ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤។

**២.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា** :

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួង ស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ។

**៣.មុខងារតំណាង** :

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចូលរួមក្នុងពិធីផ្លូវការនានា នៅតាមបណ្តាខេត្ត ក្រុង និងរាជធានីភ្នំពេញ

-ត្រៀមរៀបចំវេទិកាតាមភូមិភាគ សិក្ខាសាលា និងពិធីសំណេះសំណាលផ្លូវការផ្សេងៗ

-ត្រៀមទទួលមន្ត្រីរាជការ យុវជន សិស្ស និស្សិត និងសាធារណជនមកទស្សនកិច្ចនៅព្រឹទ្ធសភា។

**៤.មុខងារសហប្រតិបត្តិការអន្តរជាតិ និងទំនាក់ទំនងសាធារណៈ** :

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអង្គទូតនានា

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទៅបំពេញបេសកកម្មក្រៅប្រទេស

-ការចូលរួមវេទិកា APPF នាខែមករា ឆ្នាំ២០១៩ នៅខេត្តសៀមរាប

-ការចូលរួមមហាសន្និបាត AIPA នាខែកញ្ញា នៅសាធារណរដ្ឋសិង្ហបុរី

-ការចូលរួមកិច្ចប្រជុំប្រធានសភាអាស៊ី-អឺរ៉ុប នៅប្រទេសតួកគី

-ការចូលរួមកិច្ចប្រជុំកំពូលនៃក្របខ័ណ្ឌជាដៃគូសភាអាស៊ី-អឺរ៉ុប ASGP នៅប្រទេសព្រុចសែល

-ការចូលរួមមហាសន្និបាត IPU និង ASGP នាខែតុលា នៅទីក្រុងហ្សឺណែវ នៃប្រទេសស្វីស

-ត្រៀមរៀបចំដំណើរទស្សនកិច្ចផ្លូវការក្នុងឱកាសខួបទី៦០ឆ្នាំ នៃទំនាក់ទំនងការទូត នាខែតុលា នៅសាធារណរដ្ឋប្រជាមានិតចិន

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា

-ត្រៀមអនុវត្តន៍កម្មវិធីជាមួយ(APF)

-ត្រៀមចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលចាត់ចែងដោយវិទ្យាស្ថានសភាកម្ពុជា(PIC)។

**៥.មុខងារអភិវឌ្ឍន៍ស្ថាប័ន** :

-ការងារតាមដានការសុំជំនួយពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន រួមមានការកសាងអគារសាលប្រជុំពេញអង្គថ្មី និងសម្ភារៈបរិក្ខារសម្រាប់ដំណើរការនីតិកាលទី៦

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ ការសន្សំសំចៃទឹក ភ្លើង ការគ្រប់គ្រងការប្រើប្រាស់ Internet

-ការសិក្សារៀបចំ TV-online របស់ព្រឹទ្ធសភា និងបង្កើនការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងការងារប្រចាំថ្ងៃ

-ការចាប់ផ្តើមរៀបចំប្រព័ន្ធ Website/Webpageក្នុងកម្រិតអគ្គនាយកដ្ឋាន និងគណៈកម្មការ

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល គ្រប់គ្រងបុគ្គលិក តាមប្រព័ន្ធព័ត៌មានវិទ្យា កសាង Program និង Software ដើម្បីអនុវត្តតាមអង្គភាព និងការបណ្តុះបណ្តាលក្នុងនោះចូលអនុវត្តកម្មវិធី Eបណ្ណាល័យ និង E បណ្ណសារ

-អនុវត្តគម្រោងបច្ចុប្បន្នភាពរចនាសម្ព័ន្ធអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាតាមតម្រូវការថ្មី

-សិក្សាអំពីការធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធតួនាទី ភារកិច្ចរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តការសិក្សាអំពីការបង្កើតអគ្គនាយកដ្ឋានស្រាវជ្រាវ និងអគ្គនាយកដ្ឋានពិធីការ និងទំនាក់ទំនងអន្តរជាតិ

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ទំនាក់ទំនងជាថ្មីជាមួយភាគីវៀតណាម ដើម្បីបន្តអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) និងការបំពាក់សម្ភារៈបរិក្ខារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (ដំណាក់កាលទី២)

-ជំរុញការស្នើសុំអាហារូបករណ៍ និងដាក់ពាក្យប្រលងអាហារូបករណ៍ពីប្រទេសផ្សេងៗទៀតឆ្នាំ២០១៨

-ត្រៀមធ្វើជំរឿនសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស និងតម្រូវការៗ

## III.សេចក្តីសន្និដ្ឋាន

ក្នុងខែសីហានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មលើសេវាទ្រទ្រង់មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ មុខងារតំណាង និងផ្តល់សេវាជូនថ្នាក់ដឹកនាំសមាជិក សមាជិកាព្រឹទ្ធសភាបានដោយរលូនៗ ចំពោះមុខងារអភិវឌ្ឍន៍ស្ថាប័ន បានបន្តយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍធនធានមនុស្ស បង្កើនសមត្ថភាពស្រាវជ្រាវ និងភាសាបរទេសៗ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានថ្មីៗ ដើម្បីជានាបាននូវសេវាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់ជូនអតិថិជនរបស់ខ្លួនៗ ចំណែកមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានបន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង និងក្រៅប្រទេសសម្រាប់បម្រើឱ្យព្រឹទ្ធសភានីតិកាលទី៤ ដំណើរការកាន់តែល្អប្រសើរៗ ព្រឹទ្ធសភានីតិកាលទី៤ ត្រូវដើរតួជំនួសមុខអង្គការនីតិប្បញ្ញត្តិកម្ពុជាក្នុងក្របខ័ណ្ឌ AIPA IPU ព្រមទាំងក្របខ័ណ្ឌសភាអាស៊ាន-អឺរ៉ុប និងអាស៊ី-អឺរ៉ុប នាពេលខាងមុខ ។ គ្រប់យន្តការបានដំណើរការ និងកសាងជាបណ្តើរៗនូវផែនការយុទ្ធសាស្ត្រប្រចាំនីតិកាលទី៤ និងកម្មវិធីការងារប្រចាំឆ្នាំ ឆមាស ត្រីមាស

និងប្រចាំខែ ដើម្បីអនុវត្តថវិកាកម្មវិធីឱ្យបានល្អប្រសើរ។

រដ្ឋសភា និងរាជរដ្ឋាភិបាលអាណត្តិទី៦នឹងបង្កើតឱកាសថ្មី សម្រាប់ព្រឹទ្ធសភាយើងធ្វើដំណើរទៅមុខប្រកបដោយគុណភាព និងប្រសិទ្ធភាពជាងមុន។

ថ្ងៃព្រហស្បតិ៍ទី៣ ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័កព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨

អគ្គលេខាធិការ

អ៊ឹ-សារឿន